មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0189**

**សម្ភាសជាមួយឈ្មោះ នួន ឆាន់ឌឿន ភេទប្រុស អាយុ៥៨ឆ្នាំ**

**មុខងារខ្មែរក្រហមៈ “កងចល័តទំនប់ត្រពាំងថ្ម”**

**រស់នៅភូមិចក្រី ឃុំជប់វ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា**

**០០ៈ៣៨ៈ៣៧**

**១៥ទំព័រ**

ដារ៉ា : ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ ឈ្មោះអីដែរ?

ឆាន់ឌឿន : នួន ឆាន់ឌឿន ។

ដារ៉ា : ចុះម៉េចគេហៅលោកគ្រូ ចក់?

ឆាន់ឌឿន : ហៅគ្រូចក់ ។

ដារ៉ា : នួន ឆាន់ឌឿន ។

ឆាន់ឌឿន : បាទ!

ដារ៉ា : គេហៅក្រៅឈ្មោះ ចក់?

ឆាន់ឌឿន : បាទ!

ដារ៉ា : ស្រុកកំណើតរបស់លោកគ្រូនៅណា?

ឆាន់ឌឿន : នៅនេះឯង ។

ដារ៉ា : ភូមិអីគេ?

ឆាន់ឌឿន : ភូមិចក្រី ។

ដារ៉ា : ឃុំអីគេ?

ឆាន់ឌឿន : ជប់វ៉ារី ។

ដារ៉ា : ស្រុកព្រះនេត្រព្រះ ។ ចឹងកើតជានៅភូមិនឹង ហើយរស់នៅភូមិនឹងទៀតរាល់ថ្ងៃនឹង ។

ឆាន់ឌឿន : បាទ! នោះហើយ ។

ដារ៉ា : គ្រួសារលោកគ្រូឈ្មោះអីដែរ?

ឆាន់ឌឿន : អែល សាលឿម ។

ដារ៉ា : លោកគ្រូមានអាយុប៉ុន្មានដែរ?

ឆាន់ខឿន ៖ ខ្ញុំនោះ ៥៤ ។

ដារ៉ា ៖ ចុះគ្រួសារលោកគ្រូ?

ឆាន់ខឿន ៖ អាយុ៥២ ។

ដារ៉ា ៖ គាត់ស្រុកកំណើតនៅនឹងដែរ?

ឆាន់ខឿន ៖ នៅត្រពាំងថ្មស្រុកកំណើត ។

ដារ៉ា ៖ ហើយលោកគ្រូមានកូនចៅប៉ុន្មាននាក់?

ឆាន់ខឿន ៖ ៤នាក់ ។

ដារ៉ា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ឆាន់ខឿន ៖ ប្រុស១ ស្រី៣ ។

ដារ៉ា ៖ ហើយលោកគ្រូមានបងប្អូនប៉ុន្មាននាក់?

ឆាន់ខឿន ៖ បងប្អូន៣នាក់ ។

ដារ៉ា ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឆាន់ខឿន ៖ ស្រី១ ប្រុស២ ។

ដារ៉ា ៖ ពីដើមលោកគ្រូបានរៀនបានសូត្រដែរ?

ឆាន់ខឿន ៖ រៀន ។

ដារ៉ា ៖ រៀនដល់ថ្នាក់ទីប៉ុន្មាន?

ឆាន់ខឿន ៖ ថ្នាក់ទី៣ ។

ដារ៉ា ៖ ថ្នាក់ទី៣រៀនបានច្រើន?

ឆាន់ខឿន ៖ អឺ!

ដារ៉ា ៖ នៅសាលាណា?

ឆាន់ខឿន ៖ សាលាអនុវិទ្យាល័យក្រឡាញ់ ។

ដារ៉ា ៖ នឹងនៅក្នុងជំនាន់?

ឆាន់ខឿន ៖ លន់ នល់ ។

ដារ៉ា ៖ រៀនដល់ឆ្នាំណា?

ឆាន់ខឿន ៖ ដល់ឆ្នាំ៧៥ ៗសន្តិភាព អាពតចូល ។

ដារ៉ា ៖ ចូលមកពេលឆ្នាំ៧៥ ប៉ុលពតចូលនឹង គ្រូលែងបានរៀនទៀត?

ឆាន់ខឿន ៖ បាទ!

ដារ៉ា ៖ ចឹងពេលអាពតចូលមកដល់ភូមិលោកគ្រូ ប៉ុលពតធ្វើម៉េចទៅចំពោះអ្នកស្រុកអ្នកភូមិ?

ឆាន់ឌឿន ៖ ជម្លៀសចេញអត់មាននៅនេះទេ ជម្លៀសតាមភូមិ ជម្លៀសចេញទៅនៅតាមជនបទ។

ដារ៉ា ៖ ចុះក្រុមគ្រួសារលោកគ្រូទៅណា?

ឆាន់ឌឿន ៖ ទៅទាំងអស់គ្នា ទៅនៅអន្លង់វិល នៅសំរោងខាងទឹកជោរ។

ដារ៉ា ៖ នៅសំរោង?

ឆាន់ឌឿន ៖ បាទ!

ដារ៉ា ៖ មិញលោកគ្រូបាននិយាយដល់ពេលប៉ុលពតចូលភូមិឆ្នាំ៧៥នឹង លោកគ្រូជម្លៀសទៅភូមិសំរោង ទាំងក្រុមគ្រួសារម៉ង?

ឆាន់ឌឿន ៖ បាទ!

ដារ៉ា ៖ ចុះភូមិលោកគ្រូប្រជាជនខាងណាមករស់នៅវិញ?

ឆាន់ឌឿន ៖ ទេ! ពួកមកពីភ្នំពេញ គ្រប់តែកន្លែងដាក់។

ដារ៉ា ៖ ចឹងបានន័យថាមនុស្សថ្មីមកនៅក្នុងភូមិ។

ឆាន់ឌឿន ៖ ទេ! ចង់សួរៗម៉េច?

ដារ៉ា ៖ ចង់សួរថាពេលដែលប៉ុលពតចូលមកឆ្នាំ៧៥នឹង គ្រួសារលោកគ្រូ ក៏ដូចជាអ្នកភូមិនៅក្នុងភូមិរបស់លោកគ្រូនឹង គេជម្លៀសទៅភូមិផ្សេង ចឹងនៅក្នុងភូមិរបស់លោកគ្រូ អ្នកណាមកនៅវិញ?

ឆាន់ឌឿន ៖ មិនដឹងទេ ពួកអានឹង អាដូចនៅតាមថ្នល់ចេះ ពួកអានៅតាមការដ្ឋានដីរំដោះវាមកនៅយើងដែលបាននៅអាតាមថ្នល់នេះ។

ដារ៉ា ៖ អត់ឲ្យប្រជាជននៅ?

ឆាន់ឌឿន ៖ ឲ្យអ្នកដែលពួកសម័យ៧៥ ពួកសម័យលន់ នល់ គេហៅ៧៥នឹង ពួកអាដីរំដោះគេមកនៅតាមមាត់ថ្នល់នេះ គេមកនៅទៅ យើងទៅនៅឆ្ងាយមេឃដី។

ដារ៉ា ៖ ចឹងជម្លៀសទៅសំរោងនឹង លោកគ្រូនៅជាមួយនឹងក្រុមគ្រួសារ ហើយម៉េច?

ឆាន់ឌឿន ៖ នៅៗជាមួយក្រុមគ្រួសារ អាគេធ្វើស្រែសហករណ៍រួមទៅ បានម៉ាឆ្នាំ បានគេឲ្យយើងដើរចល័ត។

ដារ៉ា ៖ ពូចាំ អ្នកណាប្រធានសហករណ៍ពូ?

ឆាន់ឌឿន ៖ អូ! អ្នកណាទេ ដែលបាននៅ ចាប់ឲ្យចេញ ពួកនោះងាប់អស់ហើយ តាដែលមូលដ្ឋាន ចាស់ គាត់ចាស់ងាប់អស់ហើយ ។

ដារ៉ា ៖ គាត់ឈ្មោះអីដែរ?

ឆាន់ឌឿន ៖ អត់ស្គាល់ មិនសូវបានយកចិត្តទុកដាក់ ។

ដារ៉ា ៖ ចឹងពេលនៅធ្វើស្រែធ្វើអីក្នុងភូមិបានម៉ាឆ្នាំទៅ លោកគ្រូគេឲ្យចូលកងចល័ត?

ឆាន់ឌឿន ៖ អឺ!

ដារ៉ា ៖ ចូលកងចល័តដំបូងនៅកងណា ហៅកងអីគេ?

ឆាន់ឌឿន ៖ កង តាចាន់នោះក៏ងាប់ទៀត ទៅបរ គេវៃចោលបាត់ ។

ដារ៉ា ៖ ឈ្មោះ ចាន់?

ឆាន់ឌឿន ៖ បាទ!

ដារ៉ា ៖ គាត់ជាប្រធានកងរបស់ពូ?

ឆាន់ឌឿន ៖ បាទ!

ដារ៉ា ៖ ហើយក្នុងម៉ាកងរបស់លោកគ្រូ មានគ្នាប៉ុន្មាននាក់?

ឆាន់ឌឿន ៖ អូ! ប៉ុន្មាននាក់ ម៉ាកងធំនេះ១០០នាក់ ៣០នាក់ម៉ាកងតូច ។

ដារ៉ា ៖ ចឹងលោកគ្រូនៅកងតូច?

ឆាន់ឌឿន ៖ បាទ!

ដារ៉ា ៖ ប្រធានកងលោកគ្រូមិញឈ្មោះ តាចាន់?

ឆាន់ឌឿន ៖ តាចាន់ ។

ដារ៉ា ៖ ស្លាប់ហើយ?

ឆាន់ឌឿន ៖ ស្លាប់ ។

ដារ៉ា ៖ ហើយកងរបស់លោកគ្រូនឹង ច្រើនធ្វើការងារតាមម្តុំណា?

ឆាន់ឌឿន ៖ ដើរលើកអាទំនប់គួស្រែះៗរួចដើរចល័តទៅកងវ៉ាៗរួច ច្រើនកន្លែង ។

ដារ៉ា ៖ ចុងក្រោយដល់ត្រពាំងថ្ម?

ឆាន់ឌឿន ៖ហ្នឹងហើយដល់ត្រពាំងថ្ម ។

ដារ៉ា ៖ ចឹងលោកគ្រូបានចូលរួមលើកទំនប់ត្រពាំងថ្មដែរ?

ឆាន់ឌឿន ៖ លើកៗបានប្រហែលម៉ាខែជាង ចល័តទៅទៀតទៅ ។

ដារ៉ា ៖ ពេលដែលលោកគ្រូទៅដល់ កន្លែងទំនប់អាងត្រពាំងថ្មនឹង អាងត្រពាំងថ្មមានរូបរាងជាទំនប់ជាអីនៅ?

ឆាន់ខឿន ៖ រូបរាងជាទំនប់ បូរាណ ថ្មបាយក្រៀមៗ ប្អូនស្គាល់ស្ពានរាបគេហៅស្ពានរាបគេចាស់នោះឯងផ្លូវគេវាកាត់អូរ ប៉ុន្តែថ្មបាយក្រៀមធំៗប៉ុននេះគេតំរៀប ។ ហើយទំនប់នោះវាចាប់ចាក់ទៅដល់ថ្មពួកៗ ហើយអាផ្លូវនោះចាក់ទៅដល់អន្លុរ មិនចាក់ជិតទេ លើកនោះ លើកតាមផ្លូវចាស់បូរាណគេ ។

ដារ៉ា ៖ ចឹងលោកគ្រូទៅ កងលោកគ្រូដដែល ដែលទៅលើក?

ឆាន់ខឿន ៖ អឺ! បែងៗបែក គេបំបែក...ទៅពួកនិរតីមក ។ អានិរតីពេលនោះវាចាប់ពួកពាយ័ព្យចាប់ ជីវិតទីណែងទៅ ។

ជាតា ៖ ប្រហែលឆ្នាំប៉ុន្មានទៅ?

ឆាន់ខឿន ៖ ៧៨ៗដែលវាចូលមក ។ មើលយើងរំដោះបាន៩០ប៉ុន្មាន ។

ដារ៉ា ៖ ៧៥?

ឆាន់ខឿន ៖ ទេ! ដែលវៀតណាម ។

ដារ៉ា ៖ ៧៩ ។

ឆាន់ខឿន ៖ វៀតណាម៧៩ អាចុង៧៧ ៧៨ ដែលពួកអានិរតីមកវៃពួកពាយ័ព្យ ចាប់ពួកមេប្រធានវរៈយកទៅវៃចោលអស់ ។

ដារ៉ា ៖ មានស្គាល់ឈ្មោះខ្លះទេ ប្រធានវរៈ ប្រធានអី?

ឆាន់ខឿន ៖ គាវ៉ាល់ក្តាប់រួមផ្ទាល់ទាំងអស់ អានោះមេប្រធានវរៈ បើយើងនិយាយការពិតទៅខ្ញីគេថាជាទាហានវរៈសេនាធំ កាំភ្លើងខ្ញី ។ ធ្វើការលើកទំនប់ជីកប្រឡាយទៅ ដល់ខាងតំបន់ថាក្បត់ស្អីៗ ក៏យើងតូចតាចនេះចាំតែមើលចាប់យកទៅវៃចោលអស់ ។ ពួកនិរតីអានិយាយចឹងៗ ពួកខាងកំពង់ចាម ខាងតាកែវមកត្រួតនឹង ។ ត្រួតទៅពួកកម្មាភិបាលដែលនៅតាមចល័តនោះ ចាប់ចូលយកទៅវៃចោលអស់ ។ ខ្ញុំជិតនៅរត់ដែរ គេចវង្វេង ។

ជាតា ៖ ពេលហ្នឹងពូកំពុងធ្វើអី?

ឆាន់ខឿន ៖ លើកដី ។

ជាតា ៖ លើកដីនៅត្រពាំងថ្ម?

ឆាន់ឡឿន ៖ នោះហើយ ដល់ពេលនេះពេលដែលគេចាប់ គេឲ្យខ្ញុំម៉ាកងតូច១៥នាក់ ឲ្យទៅលើកទំនប់នៅស្ពានស្រែង បានចេញទៅ បានរួចខ្លួន អាកំពុងតែវល់វេក។ អាមេពួកដែលប្រធានសហករណ៍ ប្រធានសង្កាត់អី ចៅហ្វាយស្រុកអីនៅតាមភូមិស្រុកអីគេចាប់យកដាក់ឡាន។ ពួកអានេះចេះ វាដូចថាមេមួយ អាប្រធានសន្តិសុខ ឡានវាឲ្យដើរចាប់ដូចថាស្គាល់ទឹកដី តំបន់៥យើងនេះ ស្គាល់វាដើរចាប់ ដើរហៅវាឲ្យដើរប្រមូលអានេះស្គាល់ៗ។ ឲ្យដើរប្រមូលបាន ចាប់បានអស់ហើយ សួរថាអស់ហើយ អស់អាដើងថាវាស្គាល់ អាមេសន្តិសុខអស់រួច ចាប់អាមេសន្តិសុខ ចាប់យកវ៉ៃចោលទៀត។ អូ! ខ្លាំងទៀត។

ដារ៉ា ៖ មុនដំបូងអាមេសន្តិសុខអ្នកដើរចាប់ ដើរប្រមូល?

ឆាន់ឡឿន ៖ ហ្នឹងហើយដូចយើងថា ប៉ូលីសខេត្ត ខាងព្រហ្មទណ្ឌ អានោះហើយដើរចុះចាប់ផ្ទាល់។ ឡានមួយស្អែក យប់ព្រឹកនេះ ស្អែកចាប់ពីផ្សារតូច ប្អូនឯងធ្វើប្រធានសហករណ៍ចឹងចាប់ដាក់ឡាន។ ខាងស្អែកទៅទឹកជោរ ដូចថាខ្ញុំធ្វើប្រធានសហករណ៍ចឹង ហៅដាក់ឡានមកនេះអស់។

ដារ៉ា ៖ យកទៅសម្លាប់នៅណា?

ឆាន់ឡឿន ៖ សម្លាប់នឹង ពុតាមគេនិយាយម៉ាជួរចំការខ្នុរនឹងឯង គេថាឃើញឆ្អឹងខ្មោចច្រើន។

ដារ៉ា ៖ ចំការខ្នុរ នៅក្នុងទឹកដីភូមិអីគេ?

ឆាន់ឡឿន ៖ នៅនឹងស្វាយនឹងឯង ទៅសួរគេដឹងហើយ ខាងម៉ាជួរទៅខាងលិច ខាងភ្នំបាក់ តាមពុគេនិយាយម៉ាជួរនឹង។ អូ! សម្លាប់អស់ច្រើន តាមគេនិយាយ។

ដារ៉ា ៖ ពេលនឹងពួកនិរតីមក?

ឆាន់ឡឿន ៖ នោះហើយ និយាយពីសម្លាប់។ សម្លាប់ច្រើនណាស់ ចំការខ្នុរផង អាភ្នំបាក់ ឲ្យតែកន្លែងណាស្ងាត់ កន្លែងជ្រោះអីវាសម្លាប់ចោល។ ហើយពេលនោះហើយ ពួកខ្ញុំនៅបានប៉ុន្មានខែ ក៏ទៅនៅស្ពានស្រែងនោះ។ ដល់ពេលនេះទៅ យើងតូចតាច អត់មានពិបាកបារម្ភអី ស្រេចតែគេទៅ ធ្វើម៉េចធ្វើតែគេទៅ។ យើងចេះទៅណាក៏ទៅ ស៊ីអំបិល ស៊ីប្រហុក ចង់ឆាប់ចង់រស់។ មិនទៅធម្មតាណា បបរវេទនាចុយម្រ៉ាយ ហូតបបរ សុទ្ធតែគុលចេក មិនធម្មតាដែលខ្ញុំឆ្លងកាត់ មិនដែលបះទៀតគ្គិលចេកៗដែលដឹកបានៗ បបរស៊ីនៅនឹង។ ហើយយើងវេទនា យើងចល័តមានទៅបានស៊ីអីណា ដើមចេកបានយកមកអាបបរម៉ាចានប៉ុននេះ ស៊ីរួចឡើងឃ្លានចុយម្រ៉ាយឃ្លានវេទនា។ ប៉ុន

តែដេកគិតឃើញថា បើបានដូចកាល៧៩ នៅផ្ទះបានអង្ករបានម្ហូបនេះ ម្ហូបនោះស៊ី នឹកឃើញឃ្លាន បានម៉ានឹកឃើញ ៗ បានថាអាសម័យរបបនេះទៅ អូ!មិនធម្មតាទេ ចុះពួកប្អូនៗទាំងអស់គ្នាមិនបានកើតទាន់ណា អត់ទាន់ទេ មិនធម្មតាទេ គិតទៅអារបប អាត្រូវគ្រាប់នេះ អូ!ខ្លាំង ៗ

ដារ៉ា : កងលោកគ្រូ ពេលដែលទៅលើកនឹងកងលោកគ្រូ លើកនៅជួរមុខព្រួញកន្លែងណា?

ដាតា : ដូចថាស្ពាន៣ចឹង ស្ពានទី១ ស្ពានទី២ ដល់ស្ពានទី៣ ពូលើក?

ឆាន់ឡឿន : ទេ! លើកខ្ញុំលើកចំពាក់កណ្ដាលស្ពានទី១ មកស្ពានទី២ ៗ

ដារ៉ា : លើកតែកន្លែងនឹងសុទ្ធសាធ?

ឆាន់ឡឿន : ហ្នឹងហើយ លើករួចទៅ អាណាតាមដើងៗ អាណាលើកតាមដៃៗកទៅៗ កាលនោះ ប្រជុំស្រុកច្រើន មិនមែនលើកតែយើងទេ ៗ វាស្រុកៗមិនចេះតិចទេ ថ្មពួក ស្វាយចេក ម៉ាជួរស្រុកព្រះនេត្រព្រះ ភ្នំស្រុក បុកទៅទាំងអស់ លើកបុកតែកន្លែងមួយ បានវាឆាប់បានរួច បើលើកតែពួកយើង បើលើកតែពួកយើងដែលលើកកើត ៗ

ដារ៉ា : ចុះកន្លែងមុខព្រួញរបស់លោកគ្រូនឹង លើករបៀបជាខ្នងទំនប់នឹង?

ឆាន់ឡឿន : ហ្នឹងហើយលើកខ្នងទំនប់ ៗ

ដារ៉ា : ខ្នងទំនប់ប៉ុន្មាន ទំហំប៉ុន្មាន?

ឆាន់ឡឿន : ទទឹង៨ម៉ែត្រ ខ្នងលើកកំពស់៥ម៉ែត្រអានឹងចឹង ៗ

ដារ៉ា : ចឹងលោកគ្រូត្រូវចែកដែនការម៉ាថ្ងៃប៉ុន្មានម៉ែត្រគីប?

ឆាន់ឡឿន : ម៉ែត្រគីប ២ម៉ែត្រ គេបែងចែកយើងទៅ ២ម៉ែត្រគីប ១ម៉ែត្រគីប តាមកម្លាំងស្គមធាត់ ៗ

ដារ៉ា : ចឹងលោកគ្រូកាលជំនាន់នឹងលើកប៉ុន្មានម៉ែត្រគីបម៉ាថ្ងៃ?

ឆាន់ឡឿន : អូ! ខ្ញុំម៉ាម៉ែត្រជាងបន្តិចៗជាមួយគេដែរ គ្នាយើងច្រើនស្គមៗជួយគ្នា បានម៉ាខែទៅ បានឈប់លើក គ្រាន់ជួសជុលនៅ ៗ

ដារ៉ា : កាលនឹងក្រៅពីតាវ៉ាល់ មានអ្នកណាផ្សេងទៀត ដែលជាថ្នាក់ដឹកនាំ?

ឆាន់ឡឿន : កាលនោះនិរតី ជួរនិរតី ៗ

ដារ៉ា : ពេលកាលនៅជំនាន់តាវ៉ាល់មានពីណាខ្លះទៀត ក្រៅពីតាវ៉ាល់?

ឆាន់ឡឿន : មិនដឹងទេ ឃើញតែតាវ៉ាល់ ដំនៀរគាត់ដឹកនាំពាយ័ព្យ ៗ

ដារ៉ា : ពូដែលស្គាល់ ឃើញផ្ទាល់ទេ?

ឆាន់ខៀន :	ឃើញ ។

ដារ៉ា :	គាត់មានរូបរាងម៉េច?

ឆាន់ខៀន :	ស្គមខ្មៅ ។

ដារ៉ា :	ហើយពេលដែលមើលមុខគាត់ ទំនងគាត់កាចទេ?

ឆាន់ខៀន :	ទេ! អត់កាចប៉ុន្មានទេ ធម្មតា បេះដែរកាលនឹង សាស្ត្រាចារ្យ គេរើចោលទៅហើយ ។

ដារ៉ា :	ចឹងពូរស់នៅនឹង ម៉ោងពេលពូចូលធ្វើការម៉ោងចុះអីម៉ោងប៉ុន្មាន នៅត្រពាំងថ្ម?

ឆាន់ខៀន :	ម៉ោង១ វាមានកំណត់ ។

ដារ៉ា :	ពេលព្រលឹមចឹង ពូចូលធ្វើការម៉ោងណា?

ឆាន់ខៀន :	ធ្វើការឯណា ។

ដារ៉ា :	ចុះទៅវែកដី ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ឆាន់ខៀន :	អូ! កំណត់ទេ ជួនកាលគេឲ្យធ្វើយប់ ។

ដារ៉ា :	មានធ្វើយប់ទៀត?

ឆាន់ខៀន :	ក្រោកពីយប់ទៅ យើងចង់រួចទៅ យើងធ្វើពីយប់ទៀត ក្រោកម៉ោង៤ ម៉ោង៣កន្លះ ទៅតាមតែលទ្ធភាពដែលយើងចង់បានរួច យើងទៅរកត្រីស៊ីទៅ កំណត់តែ១ម៉ែត្រគីប ២ម៉ែត្រអីទៅ យើងខំលើកទៅបានរួច ។

ដារ៉ា :	ចឹងមិនកំណត់ម៉ោងពេលប៉ុន្មាន សំខាន់ធ្វើម៉េចឲ្យក្នុងម៉ាថ្ងៃ បើដាក់ផែនការថា២ម៉ែត្រ គីប យើងលើក២ម៉ែត្រហើយ យើងអាចទៅណាមកណាបាន?

ឆាន់ខៀន :	នោះហើយ ។

ដារ៉ា :	ចុះឧបមាថាពូទៅម៉ោង៣ម៉ោង៤ទៅ នៅនោះមានអ្នកចាំក្រោយលោកពូដែរ?

ឆាន់ខៀន :	មានតើ គេទៅវាស់ស្រេចៗ គេដោតដំរុយស្រេចៗ គេដោតបង្គោលស្រេចៗ គេ ដោតក្បាលល្ងាច ដោតទុកស្រេច ។

ដារ៉ា :	យើងទៅដល់យើងគ្រាន់តែឃើញកាប់ទៅ?

ឆាន់ខៀន :	គ្នាយើង១០នាក់គេវាស់១០ទៅ ។

ដារ៉ា :	មានម៉ាកងៗ ?

ឆាន់ខៀន :	នោះហើយ យើង១០នាក់ទៅ ម៉ាក្រុមៗយើងកាប់ចែកគ្នាកាប់លើក ដល់ម៉ោង៤ ម៉ោងអីទៅ ។

ដារ៉ា : ចុះក្រោកម៉ោង៨មានពេលសម្រាក?

ឆាន់ខឿន : ទេ! ឲ្យតែយើងកាប់រួចសម្រាក ។

ដារ៉ា : បាយទឹកអីគេឲ្យប៉ុន្មានពេល?

ឆាន់ខឿន : បាយទឹកបើថាលើកខ្លាំងកាលនោះគេឲ្យបាយស៊ីធម្មតាឲ្យ៣ពេល ។

ដារ៉ា : ដំបូង?

ឆាន់ខឿន : នោះហើយដំបូង ដល់ឈប់លើកអស់អានោះ ។

ដារ៉ា : ចឹងពេលដែលទៅលើកត្រពាំងថ្មនឹង បានបាយ៣ពេល?

ឆាន់ខឿន : នោះហើយ៣ពេល ។

ដារ៉ា : ចឹងកងពួកងស្រួច កងអី?

ឆាន់ខឿន : ទេ! កងធម្មតា ។

ដារ៉ា : នៅនឹងដែលមានឃើញមានអ្នកធំអីក្រៅពីតាវ៉ាល់អី គាត់ចុះទៅមើល ដូចថាអង្គការធំៗចុះទៅមើលកន្លែងធ្វើការ?

ឆាន់ខឿន : ទេ! ចុះឃើញតែនេះ គេមិនដែលឲ្យយើងទៅបៀត ។

ដារ៉ា : ក្រែងលរគេដើរលើកន្លែងខ្នងទំនប់អី យើងកំពុងលើ?

ឆាន់ខឿន : អារឿងដើរឃើញតែគេដើរ មិនដឹងលោកណា អត់ដែលស្គាល់ វាចេះតែមានទៅ ។

ដារ៉ា : មានឡានអី?

ឆាន់ខឿន : អេស្គូបអីខស្បាហ៍ទៅ យើងមិនដែលហ៊ានសួរគេ ឆាយស្រួលណាអារឿង តែឃើញដូចថាចិនចុះមក ពួកចិនចុះមកឡានតាមផ្លូវណា តិចថាទៅបៀតបានណា តាមផ្លូវអត់បៀតបានទេណា ផ្លូវមកធម្មតាទៅៗគក្រឹកគក្រេង ។ ទៅយើងនៅតាមដុំ វាស្គមៗគេឲ្យនៅតាមដុំ អាល្មមៗឆាត់ៗនៅតាមថ្នល់ទៅ ។

ដារ៉ា : ឲ្យក្មៀវមើល?

ឆាន់ខឿន : ក្មៀវមើលចេញទៅទ័ពទៅ ។

ដារ៉ា : ពេលមកម្តងៗចឹង គេមានប្រជុំដាក់ផែនការអីប្រាប់យើងទេ?

ឆាន់ខឿន : ចុះយើងមិននិយាយថាបិទចរាចរ ក៏យើងមិនទៅធ្វើអី បិទតែគេទៅតាមដុំតាមអី ។

ដារ៉ា : ចុះពូមានដឹងថា ដូចថាមានពុការខ្សឹបខ្សៀវថាអ្នកណាផ្តួចផ្តើមគំនិតអីធ្វើអាងត្រពាំងថ្មដែរ?

ឆាន់ឌឿន ៖ ដឹងអ្នកណាគេផ្ដួចផ្ដើម ស្រាប់តែដល់ពេលនាំគ្នាលើកទៅ វាមិនដឹងថាផែនការមកពីខាងណាខាងណៃមិនដឹងទេ ស្រាប់តែគេថា ផែនការនាំគ្នាលើកអាងត្រពាំងថ្ម គ្រប់ស្រុកគ្រប់ស្រែក៏ទៅទាំងអស់គ្នា យើងអត់ដឹង យើងទៅ អត់បានសួរនាំ ។

ដារ៉ា ៖ ចឹងក្រោយពីលើកអាងត្រពាំងថ្ម ពូត្រូវផ្លាស់ប្ដូរមកណាវិញ?

ឆាន់ឌឿន ៖ នៅភូមិ នៅទឹកដោរ ។

ដារ៉ា ៖ ថាមកស្ពានស្រែង?

ឆាន់ឌឿន ៖ ស្ពានស្រែងនោះដកនៅម៉ាប្រាវទេ ដល់ពេលយើងទៅផ្ទះវិញ ទៅតាមសហករណ៍វិញ ។

ដារ៉ា ៖ ចឹងត្រឡប់មកវិញ មកដល់សហករណ៍នឹង នៅភូមិណា សហករណ៍ណា?

ឆាន់ឌឿន ៖ នៅទឹកដោរ ភូមិថ្មី ទឹកដោរ ។

ដារ៉ា ៖ សហករណ៍ទឹកដោរវិញ?

ឆាន់ឌឿន ៖ អឺ!

ដារ៉ា ៖ អានឹងគេឲ្យធ្វើអីវិញហើយ?

ឆាន់ឌឿន ៖ ធ្វើស្រែធម្មតា ។

ដាតា ៖ នៅកន្លែងត្រពាំងថ្មនឹង ដូចកន្លែងស្នាក់នៅ ហូបទឹកហូបអីម៉េចដែរ?

ឆាន់ឌឿន ៖ អូ! វេទនាចុយម្រ៉ាយហើយ មុជទឹកមិនមានទឹកមុជផង ទៅលើកខែប្រាំងហើយមនុស្ស រាប់ម៉ឺននាក់ រាប់ម៉ឺនរាប់សែន ។

ដាតា ៖ ចឹងបានទឹកអីពិសារ?

ឆាន់ឌឿន ៖ ឡានដឹកឲ្យ ដឹកទឹកឡានទៅយកមកចែកគ្នា បើបះមានភ្លៀងមិនអីទេ បើអត់ភ្លៀងដឹកបានតែទឹកដឹក មុជវេទនាភក់ មិនធម្មតាជណ្ដើមគ្នាដឹក ស៊ីបាយរួច មានតែទឹកអត់ចាក់រហេរហាចបាន ។

ដាតា ៖ គេចែកឲ្យ?

ឆាន់ឌឿន ៖ ចែកតើ ។

ដាតា ៖ ម៉ាថ្ងៃប៉ុន្មាន?

ឆាន់ឌឿន ៖ ទេ! យើងទៅដឹកតាមកម្រិត មិនចេះទៅផង ទៅមុជផ្ដេសផ្ដាសបានទេណា ទឹកវាក្រចុះលើកមានទឹកពីណា អាងលើកគ្រាន់បានរៀងទម្រាំបានទឹកមក អានោះបានបរិបូណ៌មានលើកមិនស្រួល ។ និយាយពីខោអាវនេះ អំបិល ។

ដារ៉ា ៖ ប៉ុន្មានថ្ងៃបានមុជទឹកម្តង?

ឆាន់ឌឿន ៖ អូ! ៥-៦ថ្ងៃនោះ មិនស្រួល ។

ដារ៉ា ៖ មុជទឹកកន្លែងណា?

ឆាន់ឌឿន ៖ មុជតាមកន្លែងណាតែនេះទៅ ជួនកាលមានភ្លៀងម៉ាប្រាវ បេះទៅៗមុជអាត្រពាំង ដណ្ដើមគ្នាមុជ ដីក ។

ដារ៉ា ៖ តាមថ្លុកតាមអី?

ឆាន់ឌឿន ៖ នោះហើយ ។

ដារ៉ា ៖ ចុះពេលពូត្រឡប់មកធ្វើស្រែនៅទឹកដោរនេះធ្វើរហូត?

ឆាន់ឌឿន ៖ ហ្នឹងហើយធ្វើដល់សន្តិភាព ។

ដារ៉ា ៖ ធ្វើដល់ប៉ុន្មាន?

ឆាន់ឌឿន ៖ ធ្វើបានប្រហែលប៉ុន្មាននេះទៅក៏ វៀតណាមគេផ្សាយវ៉ាដ្យូទៅ មានកម្លាំងចិត្តអរចង់ស្លាប់ ។

ដារ៉ា ៖ កាលនឹងពូនៅក្នុងកំឡុងពេលនឹង ពូមានដឹងថាមានសង្គ្រាមអីជាមួយវៀតណាមជាមួយអីដែរ?

ឆាន់ឌឿន ៖ ទេ! អត់នេះទេ គ្រាន់ឌ្វីបខ្សៀវ គ្រាន់ពុតាមវ៉ាដ្យូៗវាចាក់បើកពុថាឲ្យប៉ុស្តិ៍ណាផ្សេងវ៉ៃចោល មិនមែនបេះតែបើកនឹកឃើញថាបើក ទៅចំហរវ៉ាដ្យូស្តាប់ពីនេះពីនោះ មិនឲ្យទេ ។ វ៉ាដ្យូឲ្យមានទៀត វ៉ាដ្យូថាយើងមានទាំងអស់គ្នា អត់ទេមានតែពួកផ្នែកកម្មាភិបាលវា រាយការណ៍ស្តាប់ ។ ហើយយើងអត់ទេ តែហ៊ានមានសម្លាប់ចោល ។ ដល់នេះទៅប្រជាជននៅនោះលួចបើកទៅស្តាប់ពុ ស្គាល់ខ្មែរថារំដោះរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ចូលមកអរចុយម្រ៉ាយ ។ បានវ៉ៃចោលណា វ៉ៃចោលអារឿងវ៉ាដ្យូណា តាមគេនិយាយត្រពាំងថ្មៗ បើកវ៉ាដ្យូស្រុកយើងស្រួលហើយ បានកងទ័ពវៀតណាមជួយរំដោះបានហើយយើង.......(ស្តាប់មិនបាន) ។

ជាតា ៖ ពូពុគេនិយាយហើយ ដល់ស្អែកឡើងបាត់ខ្លួនអ្នកនឹង?

ឆាន់ឌឿន ៖ ទេ! ពុគេនិយាយអ្នកត្រពាំងថ្ម ថាចូលរួចហើយដែលសព្វថ្ងៃ គេនិយាយថាគ្នាបើវ៉ាដ្យូស្តាប់ទៅ ដល់នេះវាដឹងថាយើងដឹងដែនការ យកយើងវ៉ៃចោល ។ មិនស្រួលទេ ដល់នេះទៅដឹង អរចុយម្រ៉ាយម្នាក់ៗ ។ កាលនោះដឹងស្រាប់ហើយ ថាបានបាយស៊ីដឹងគុណ មិនធម្មតាទេ បានថាឃើញយើងសព្វថ្ងៃ បានប៉ុននេះ

ចង់ប៉ុននោះទៀត ។ អូ! បាន បុណ្យគុណសម្តេចហ៊ុនសែន មិនធម្មតាទេ ជួយយើង ។ អឺ! គណៈបក្សដទៃទៀត មកយកបោះឆ្នោត បោះដល់ស្លាប់ ។ ខ្ញុំសព្វថ្ងៃ និយាយត្រង់បានរស់តែប៉ុននេះស្រួល ណាស់ហើយរបបយើងនេះ រករបបណាទៀត ។

ដាតា : ពេលពូនៅត្រពាំងថ្មនឹង ពូឃើញប្រជាជនស្លាប់ច្រើន?

ឆាន់ឌឿន : ទេ! មិនបានដឹងឲ្យឃើញទេ ។

ដាតា : មានដូចក្រុមពូ បាត់ខ្លួនបាត់អីចឹងធ្វើៗការបាត់?

ឆាន់ឌឿន : ទេ! មិនសូវទេ អត់ ធម្មតា ។

ដាតា : អ្នកឈឺអ្នកអីម៉េចដែរ?

ឆាន់ឌឿន : ទេ! មិនដឹងទេ យើងទៅដេកពេទ្យទៅ តែគេទៅ ។

ដាតា : មានអ្នកឈឺស្លាប់នៅកន្លែង?

ឆាន់ឌឿន : អត់ទេ អត់មាន ។ ទៅដេកពេទ្យអារឿងសម្លាប់យើងដឹងហើយ ឮសូរគេថា ប៉ុន្តែយើង អត់ឃើញ ។

ដារ៉ា : ចុះពូដែលជួបប្រទះ?

ឆាន់ឌឿន : អត់ដែលឮ អត់ដែលឃើញទេ មានណាមានតែយើងខំទៅធ្វើការ អាណាទៅស៊ីបនោះ ទៅស៊ីបផ្តេសផ្តាសម៉េចចុះ អត់បានទេ ។

ដារ៉ា : ចឹងពូរឿងរ៉ាវអស់នឹង ពូធ្លាប់ដែលនិយាយរឿងការលំបាកវេទនាសម័យនោះ?

ឆាន់ឌឿន : ហ្នឹងហើយ ចេះតែប្រាប់ទៅ ប្រាប់ថាឲ្យយើងខំទៅ យើងថាសម័យរបបនេះយើងបាន សប្បាយចុះពួកឪពុកម្តាយ ដែលខ្ញុំខំដែលនៅកាលនោះវេទនាប៉ុនណា យើងគិតមើល បាយបើឃើញគ្រាប់អង្ករ វេទនាម៉ាចានមិនធម្មតាទេ ។

ដារ៉ា : ចុះពេលគ្រូបង្រៀនកូនសិស្សអី ធ្លាប់ដែរនិយាយរឿងនឹងប្រាប់?

ឆាន់ឌឿន : ប្រាប់ៗ ពួកប្អូនឯងទាំងអស់គ្នានឹងមិនដែលឆ្លងកាត់ទេ ដែលលោកគ្រូឆ្លងកាត់នោះបាន ដឹងថាវេទនាប៉ុនណា ។

ដារ៉ា : កូនសិស្សនឹងវាជឿ ឬម៉េចដែរ?

ឆាន់ឡឿន ៖ វាជឿម៉ាចំនួនដែរ នាំគ្នានិយាយលេងសើច វាជឿងដែរតើ វាជឿថាខ្ញុំជឿ ស្រេចប្អូនឯងជឿៗ បើមិនជឿដឹងធ្វើម៉េចៗ ប៉ុន្តែរំលឹកវា តែរំលឹកៗ អាថ្ងៃមើលថ្ងៃប៉ុន្មានថ្ងៃ១ មិថុនាៗ

ដារ៉ា ៖ ថ្ងៃ២០ឧសភា?

ឆាន់ឡឿន ៖ តែងរំលឹកទិវាចងកំហឹងៗ

ដារ៉ា ៖ ហ្នឹងហើយ ថ្ងៃ២០ឧសភា?

ឆាន់ឡឿន ៖ ប្រជាជនមួយចំនួន ជឿ ពួកក្មេងៗខ្លះជឿ ខ្លះមិនជឿៗ

ដារ៉ា ៖ ចុះលោកគ្រូគិតថាធ្វើម៉េច ដើម្បីឲ្យកូនក្មេងដែលអត់កើតទាន់សម័យនឹង វាជឿថាមានការលំបាក?

ឆាន់ឡឿន ៖ ឲ្យសួរម៉ែឪ យាយតាវាទៅ ថាប្អូនឯងមិនជឿ ប្អូនឯងសួរយាយតាប្អូនឯងទៅ ដែលប្អូនឯងបានហូបចុកសប្បាយសព្វថ្ងៃ បានស៊ីរាល់ថ្ងៃតើអ្នកណារំដោះបានហើយតើអ្នក ណាដែលធ្វើទុក្ខវេទនាមកដល់យើង អាពតនេះ តើអ្នកណាខ្លះហើយសួរកុងម៉ាយើង ទៅៗ អាខ្លះវាសួរថាវាមែន ហើយចុះឪពុកម្ដាយវាហើយនឹងយាយតាវាកើតទាន់ៗ

ដារ៉ា ៖ សុទ្ធតែឆ្លងកាត់?

ឆាន់ឡឿន ៖ ឆ្លងកាត់ ហើយអាក្រោយៗឪវាៗហេងស៊យអត់ទាន់ទៀត ទាន់យាយតា អស់ម៉ាវគ្គបើនិយាយការពិត អស់ម៉ាវគ្គពួកខ្ញុំទៅទៀតចប់ហើយ ស្គាល់ណាប្រវត្តិសាស្ត្រអាពតនោះអត់បានជឿទេៗ និយាយលេង អត់ជឿទេ ចង់មិនចង់ វាអត់ជឿយើងទេអី!ឯ ណាអាពត ចុះបើវារួចទៅហើយ វាផុតទៅកន្លងផុតទៅហើយ អាយើងលំបាកកាល នោះពេលដែលស៊ីបបរ២-៣គ្រាប់នឹកឃើញកាលម៉ែអញអើយបាយទាំងឆ្នាំងហូប និយាយពីលេបទឹកមាត់ អានឹងខ្ញុំនឹកវេទនាៗ

ដារ៉ា ៖ នឹកឃើញរឿងឆ្ងាញ់អីឲ្យវាបានសប្បាយចិត្ត បន្ទប់?

ឆាន់ឡឿន ៖ នោះហើយដឹងណាៗ ដេកអត់មានលក់ទេណា និយាយពីពោះវាកូរ នឹកឃើញតែឃ្លានស្មានណាបានអ្នកណាជួយព្រះអង្គអើយ និយាយលេងសើចនឹង ឆ្លងកាត់បានដឹងថាវេទនាប៉ុនណាៗ ឃើញយើងដើរកាត់ទៅ ជួនកាលឃើញពួកវាអាកម្មាភិបាលអី វាស៊ីបាយស៊ីអី ហើយយើងអត់បាយ មានស៊ីបាយ មិននិយាយលេង បបរមិនធម្មតាទេវាហៅ អាឃ្លាននេះសូម្បីតែជ្រុះអីតិចតួចក៏រើសស៊ីដែរ វាស្រួលចឹង បានថាទុក្ខវេទនា

នឹងមិនធម្មតាទេ បើថាអ្នកដឹកនាំសម័យអាពតនេះអស់ទាស់ មិនត្រូវមកធ្វើៗ ដូចខ្មែរយើងមិនសមធ្វើបដិវត្តន៍ ។

ដារ៉ា : ខ្ញុំសួរច្រើនទៅ បានត្រឹមថាអ្នកលើកទំនប់ត្រពាំងថ្ម តែអត់ដឹងថាអ្នកណាជាអ្នកផ្ដួចផ្ដើមចេញពីណា មានគម្រោងចេញពីថ្នាក់ណាៗ អត់អាចដឹងបាន ។

ឆាន់ឡឿន : អត់ដឹងទេ មិនដឹង អានេះបែបជា អឺ! ឃើញផែនការចេះតែមានថាលើកៗទៅ ក៏តាមមើលផែនការនេះ មិនមែនជាផែនការស្រុក បានអីទេ ផែនការបែបធំគេលើដីង ។ ចុះបើកម្លាំងមូលមិននេះណា ស្រុកឡើងមិនចេះតិចស្រុក ស្រុកព្រះនេត្រព្រះ ថ្មពួកស្វាយចេក ស្រុកភ្នំស្រុក ។ ចុះលើកចុះហើយ មិនធម្មតាណា ។

ដារ៉ា : អាចថាជាផែនការមកពីមជ្ឈិម ឬក៏ពីតំបន់ ពីភូមិភាគអី?

ឆាន់ឡឿន : បែបលាយគ្នាដឹង ឃើញលើកច្រើនចឹង គេឲ្យយើងលើកចេះលើកទៅ ។

ជាតា : មានដែលឮសម្ដីឪ្យបខ្សៀវដឹងថា ផែនការរបស់អ្នកណា?

ឆាន់ឡឿន : ទេ! មិនដែលមានអ្នកណាបានទៅគិតចឹង វាមិនដែលបានសួរនាំអារឿងនោះ គិតតែរឿងធ្វើម៉េចឲ្យឆ្អែត ។ ម៉ាថ្ងៃៗ គិតតែរឿងស៊ី មែនមិនមែន ប្អូនឯងដឹងស្រាប់ ។ ចុះអាយើងឲ្យស៊ីមិនគ្រប់ ហើយការងារវាច្រើន ហើយឲ្យយើស៊ីមិនគ្រប់អត់មានរឿងអីបានសួរនាំ ។ អត់សួរនាំទេគ្មានអ្នកណាដឹងគ្មានអីគេ គិតតែយើងឃើញតែគេថតរឿង សម័យអាពតអី គ្រាន់តែឃើញវេទនាចុយម្រ៉ាយអណោចអធម្មទៀត ។

ដារ៉ា : កាលលោកគ្រូធ្លាប់ឆ្ងងកាត់ ពេលអ្នកមិនធ្លាប់ឆ្លងកាត់ អាចវាធម្មតា?

ឆាន់ឡឿន : ហឺ! ក្ដៅមែន នឹកឃើញ ។

ជាតា : លោកគ្រូនៅគុំ នៅខឹង?

ឆាន់ឡឿន : អូ! ខឹងមែនទែន ។

ជាតា : ចុះដូចមានតុលាការ មានអីចឹង ពូយល់យ៉ាងម៉េចដែរ ដូចថាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចឹង ពូមានចិត្តគិតម៉េចដែរ?

ឆាន់ឡឿន : អូ! កាត់ទោសៗពួកអាចេះៗ វាកាត់ទោសធ្វើបានប្រជាជនឡើង មើលឃើញតាមទូរទស្សន៍ ឃើញប្រជាជនគរ៉ាកាត់ៗទៅ ។

ជាតា : ពូមើលតាមដានរហូតដែរ?

ឆាន់ឌឿន ៖ នោះហើយ តាមដានទៅ ពួកនោះមិនគិតរឿងខ្មែរសម្លាប់ខ្មែរគ្នាឯង អត់មានគិតគូរ ស្រណោះខ្មែរគ្នាឯង បំផ្លាញឡើងរហូតដល់ បើសព្វថ្ងៃប្រទេសយើងប៉ុននេះ ហើយគេ មានរីកចំរើនប៉ុន្មាន អាគេរីកដល់ណា ឯងទើបបានប៉ុននេះៗ វាឡើងចង់លាងឯងទៀត ឃើញថាខ្មែរយើងកម្ម គិតទៅមិនធម្មតាទេ ។ នៅនេះដែលវាវ៉ៃប្លោងដាក់មកនោះ ពួក ខុត្តរមានជ័យដាក់ឡើងប៉ុន្មានពាន់គ្រាប់ ពួកអាថៃ ។

ដារ៉ា ៖ ចឹងពួកខ្ញុំដូចជាអត់មានអីសួរលោកគ្រូច្រើនទៀតទេ បាទ!ខ្ញុំអរគុណច្រើនបានផ្តល់បទ សម្ភាសន៍ ។

ឆាន់ឌឿន ៖ បាទៗ ទេ! និយាយការពិតអ្នកលើកនេះ ត្រង់ណាឲ្យតែសួរចាស់ៗ សួរអាយុទាំងខ្ញុំអី គេដឹងទាំងអស់ព្រោះម្នាក់ៗទៅលើកទាំងអស់តែគ្នានឹងឯង ។

ដាតា ៖ នៅនេះមានច្រើនទៀត អ្នកលើកនៅត្រពាំងថ្ម?

ឆាន់ឌឿន ៖ មិនដឹងណាណៃ បើយើងមិនដែលបានជួបគ្នា រឿងចល័តវាចល័តទីណាត់ទីណែង ត្រូវ ជួបមិនជួប ប៉ះកាលនោះប៉ះគ្រូខ្ញុំនេះ លើកៗប៉ះគ្រូហមទៅផុតចឹង អត់អីទេ វាអត់ សម្លាប់ទេ ។

ដារ៉ា ៖ គ្រូ ហម គាត់ត្រូវជាលោកគ្រូរបស់លោកគ្រូ?

ឆាន់ឌឿន ៖ នោះហើយ ផុត គាត់ទើបទៅគេចផុតគេយកគាត់ដាក់ទីយោ ផុតទៅ អត់អីរស់រហូត សព្វថ្ងៃ ទៅអាមេរិចដឹង ឮថាគាត់ទៅអាមេរិច ។

ដាតា ៖ ចង់និយាយថាគាត់អ្នកចេះដឹងដែរ?

ឆាន់ឌឿន ៖ ទេ! សំណាងគាត់ គ្រាន់តែឃើញគាត់បរទេះដឹងស្អីៗខ្ញុំអត់ហ៊ានស្រែកហៅទេ ខ្លាចថា គេដឹងថាគាត់គ្រូ រួចហៅមា ហៅគ្រូ ចាប់គាត់បោះ ស្រណោះគាត់ ហៅមាៗទៅ គាត់បរទេះធ្វើងើយទៅណា ។

ដារ៉ា ៖ ចុះកាលនឹងបើដឹងថាលោកគ្រូ ថាអីចឹងម៉េចទៅ យើងមានជោគវាសនា យ៉ាងម៉េច?

ឆាន់ឌឿន ៖ ចាប់ម៉ង អត់មាននិន្នាការ ។

ដាតា ៖ តាមធម្មតា អ្នកដែលគេចាប់នឹង ប្រភេទមនុស្សម៉េចខ្លះទៅ?

ឆាន់ឌឿន ៖ ទេ! អាវាពួកក្តាប់ធំៗ ។

ដាតា ៖ អត់ទេ អ្នកត្រូវគេចាប់ មានជាគ្រូចឹង បើសិនជាគេដឹងគេចាប់ ចុះមានអ្នកប្រភេទម៉េច ទៀត ដែលគេចាប់ទៀត?

ឆាន់ឌឿន ៈ សុទ្ធតែទាហាន ។

ដាតា ៈ ហើយមានអីទៀត?

ឆាន់ឌឿន ៈ មានគ្រូ ឲ្យជាប់និន្នាការសេរី ក៏ចាប់ និន្នាការដូចថាធ្វើទាហាន ធ្វើគ្រូ ធ្វើកុម្មង់ដូរ មេកុម្មង់ដូរ ។

ដាតា ៈ ចុះជនជាតិវៀតណាមម៉េចដែរ?

ឆាន់ឌឿន ៈ មិនសូវដែលឮ មិនសូវដែលមានទេ វៀតណាមដែលពួកចាមអីធម្មតាទេ ពួកចិនអីក៏ធម្មតា សួររក ។

ដាតា ៈ ចុះបើនៅកងពូ កាលសម័យនឹងមានវៀតណាមអីនៅជាមួយពូអត់?

ឆាន់ឌឿន ៈ អត់ ធម្មតា ។

ដារ៉ា ៈ ចប់ ។

«ចប់»